**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

*ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ចេត្រ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និង អនុវត្តនីតិវិធីតាម FMIS ទាំងស្រុង ជាផ្លូវការ នៅការដ្ឋានបន្ថែម"

នាព្រឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២៥, នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា, **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** បានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធី **"ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និង អនុវត្តនីតិវិធីតាម FMIS ទាំងស្រុង ជាផ្លូវការ នៅការដ្ឋានបន្ថែម"** ដោយមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ ដែលជាតំណាងក្រសួង-ស្ថាប័ន និង តំណាងដៃគូអភិវឌ្ឍន៍ សរុបប្រមាណ ៤០០ រូប ។

ពិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រកាសជាផ្លូវការ៖ ទី១).ដាក់ឱ្យប្រើប្រាស់ FMIS នៅគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៥ រួមមាន៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យជាតិបាត់ដំបង, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និង ត្រៀមអនុវត្ត "នីតិវិធីចំណាយ និង ចលនាឥណទានថវិកាចន្តតាម FMIS ទាំងស្រុង" នៅត្រីមាសទី២ ឆ្នាំ ២០២៥ ដំណាលគ្នាជាមួយ គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៤ ដែលបានប្រើប្រាស់ FMIS កាលពីឆ្នាំ ២០២៣; ទី២).ដាក់ឱ្យប្រើប្រាស់ FMIS នៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មី ចំនួន៤៤ នៃក្រសួង-ស្ថាប័នចំនួន ១០ ផ្សារភ្ជាប់ការអនុវត្តនីតិវិធីតាម FMIS ទាំងស្រុង រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងយុត្តិធម៌, ក្រសួងរ៉ែ និងថាមពល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, អាជ្ញាធរសវនកម្មជាតិ, និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា; ទី៣).ដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា នៅ

ក្រសួង-ស្ថាប័នចំនួន ១៤ ព្រមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រួមមាន៖ ក្រសួងព្រះបរមរាជវាំង, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ, ក្រសួងអធិការកិច្ច, ក្រសួងសុខាភិបាល, ក្រសួងរ៉ែ និងថាមពល, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងធម្មការ និងសាសនា, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ក្រសួងមុខងារសាធារណៈ និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍; ទី៤).ដាក់ឱ្យអនុវត្តនីតិវិធីចំណាយ និង ចលនាឥណទានថវិកាចរន្តតាម FMIS ទាំងស្រុង នៅក្រសួង-ស្ថាប័នចំនួន ៨ ព្រមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រួមមាន៖ ក្រសួងព្រះបរមរាជវាំង, ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងផែនការ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសាធារណការ និងដឹកជញ្ជូន, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងមុខងារសាធារណៈ, និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍; ទី៥).ដាក់ឱ្យអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈតាម FMIS ទាំងស្រុង នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន ព្រមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ; ទី៦).ដាក់ឱ្យអនុវត្តចំណាយវិនិយោគថវិកាថ្នាក់ជាតិហិរញ្ញប្បទានក្នុងប្រទេសតាម FMIS នៅក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ; និង ទី៧).ដាក់ឱ្យអនុវត្តគម្រោងរៀបចំ និង អភិវឌ្ឍមុខងារលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-GP) នៅក្នុង FMIS; នាព្រឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២៥ នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា ។

ថ្លែងក្នុងពិធីខាងលើនេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានគូសរំលេចថា បច្ចុប្បន្ន FMIS មិនត្រឹមតែក្លាយជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធថវិកាកម្មជាប៉ុណ្ណោះទេ តែថែមទាំងបាននិងកំពុងជួយជំរុញការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និង ជំរុញដល់ការធ្វើវិមជ្ឈការនៃការគ្រប់គ្រង និង អនុវត្តថវិកា ជូនដល់អង្គភាពថវិកាផ្ទាល់ តាមរយៈការពង្រីកការដាក់ឱ្យអនុវត្ត FMIS ទៅដល់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្សារភ្ជាប់ជាមួយនឹងការដាក់ឱ្យអនុវត្តនីតិវិធីតាម FMIS ទាំងស្រុង ជាជំហានៗ ដើម្បីមានលទ្ធភាព គ្រប់គ្រង ចាត់ចែង និង ទទួលខុសត្រូវលើថវិការបស់ខ្លួនផ្ទាល់ តាមរយៈការអនុវត្តនីតិវិធីទូទាត់កាន់តែងាយស្រួល រហ័សតាមបែបឌីជីថល និង សម្រួលដល់ការផ្តល់សេវាសាធារណៈរបស់អង្គភាពជំនាញនីមួយៗឱ្យបានកាន់តែមានគុណភាព និង ទាន់ពេលវេលា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** បានបន្ថែមថា ជាយុទ្ធសាស្ត្រ, រាជរដ្ឋាភិបាលកំពុងដើរឈានទៅដល់របត់ថ្មីជាបណ្តើរៗ ដោយត្រូវចាប់ផ្តើមរៀបចំ និង អភិវឌ្ឍ "មុខងារលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក" ដែលហៅកាត់ថា "e-GP" ដើម្បីជួយជំរុញឱ្យការទាញប្រយោជន៍ពី FMIS បានកាន់តែច្រើនថែមទៀត ដែលធានាបាននូវការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រកបដោយតម្លាភាព, គណនេយ្យភាព, សុចរិតភាព, ភាពប្រកួតប្រជែង, ភាពយុត្តិធម៌, ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, ចីរភាព, គុណភាព, ភាពសន្សំសំចៃ និង ភាពទាន់ពេលវេលានៃការអនុវត្តផែនការលទ្ធកម្ម ។ ការអនុវត្តលទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់នៅក្នុង "យុទ្ធសាស្ត្រនៃការកែ

ទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥" និង "ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥" ។

ឆ្លៀតក្នុងឱកាសនេះ, ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានគូសរំលេច និង រាយការណ៍ដោយសង្ខេប ជូនអង្គពិធី អំពីវឌ្ឍនភាព និង សមិទ្ធផលគន្លឹះៗដែលសម្រេចបានតាមផែនការគ្រោងទុកគួរឱ្យស្ញើច-សរសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈ ក្នុងការអនុវត្តគម្រោង FMIS នៅឆ្នាំ២០២៤ និង នៅក្នុងត្រីមាសទី១ ឆ្នាំ ២០២៥ នេះផងដែរ ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ និង ថ្លែងអំណរគុណ ចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានក្រុមការងារ**, លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS, អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រុមការងារអនុវត្តគម្រោង FMIS នៅគ្រប់ការដ្ឋាន, ក្រសួង-ស្ថាប័ន, អង្គភាពថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ទីប្រឹក្សាអន្តរជាតិរបស់គម្រោង រួមទាំងគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់, ជាពិសេសសហភាពអឺរ៉ុបដែលបានចូលរួមគាំទ្រផ្នែកបច្ចេកទេស និង ហិរញ្ញ-ប្បទាន ដែលបានចូលរួមសហការជាសហថាមពលមួយ ប្រកបដោយជវភាពនៃតួអង្គតែមួយ រហូតសម្រេចបាននូវសមិទ្ធផលជាច្រើននាពេលកន្លងមក ស្របតាមចក្ខុវិស័យ និង បង្គោលចរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បាន "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និង អនុវត្តនីតិវិធីតាម FMIS ទាំងស្រុង ជាផ្លូវការ នៅការដ្ឋានបន្ថែម" ។

គួរបញ្ជាក់ផងដែរថា ចាប់តាំងពីការអនុវត្តជំហានទី១ រហូតមកដល់បច្ចុប្បន្ននេះ ការដ្ឋានដែលកំពុងប្រើប្រាស់ FMIS សរុបមានចំនួន ៣០០ ការដ្ឋាន, មុខងារប្រព័ន្ធដែលកំពុងដំណើរការមានចំនួន ៨ មុខងារ , សន្ទានកម្មជាមួយប្រព័ន្ធខាងក្រៅមានចំនួន ១៦ ប្រព័ន្ធ, របាយការណ៍ផលិតចេញពីប្រព័ន្ធសរុបមានចំនួន ៦៦ របាយការណ៍ និង អ្នកប្រើប្រាស់ប្រព័ន្ធសរុបមានចំនួន ៣.៦៦២ រូប ។ ដោយឡែកសម្រាប់ការដ្ឋានដែលកំពុងប្រើប្រាស់ FMIS Portal ជំនាន់ទី១ មានចំនួន ១.៨៧០ ការដ្ឋាន និង អ្នកប្រើប្រាស់ប្រព័ន្ធនេះសរុបមានចំនួន ៣.៣៧២ រូប ៕